ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន
លេខ: ១១១៧ ស.ព.ស.ជ.សា

# សេចក្ដីជូនដំណឹង

## ស្ដីពី រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំស្ដីពី "កិច្ចសន្ទនាជាមួយពហុភាគីពាក់ព័ន្ធរបស់សភាស្ដីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវសម្រាប់សន្តិសុខស្បៀង និងអាកាសធាតុ"

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន មេត្តាជ្រាបថា រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចសហការជាមួយលេខាធិការដ្ឋានអាយប៉ា និងមានការគាំទ្រពីអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) នឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំស្ដីពី **"កិច្ចសន្ទនាជាមួយពហុភាគីពាក់ព័ន្ធរបស់សភាស្ដីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវសម្រាប់សន្តិសុខស្បៀង និងអាកាសធាតុ៖ ជំរុញរបៀបវារៈអាស៊ានស្ដីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវ លើវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ"** ចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា ។

កិច្ចប្រជុំនេះ មានការអញ្ជើញមកចូលរួមដោយផ្ទាល់ និងតាមរយៈប្រព័ន្ធនិម្មិត (Zoom) ពីគណៈប្រតិភូជាសមាជិកអន្តរសភាអាស៊ាន (អាយប៉ា/AIPA) សមាជិកសភាកម្ពុជា អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងធនធានទឹក និងឧតុនិយម ផងដែរ។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១រដ្ឋសភា នឹងអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ថ្លែងសុន្ទរកថាបើកកិច្ចប្រជុំស្ដីពី **"កិច្ចសន្ទនាជាមួយ ពហុភាគីពាក់ព័ន្ធរបស់សភាស្ដីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវសម្រាប់សន្តិសុខស្បៀង និងអាកាសធាតុ៖ ជំរុញរបៀបវារៈអាស៊ានស្ដីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវ លើវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ"** នៅព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៦។

កិច្ចប្រជុំនេះ នឹងដំណើរការទៅ ដោយមានការចូលរួមធ្វើបទបង្ហាញពីវាគ្មិនជំនាញៗ មកពីអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) តំណាងលេខាធិការដ្ឋានអាយប៉ា គណៈកម្មការជំនាញរដ្ឋសភា និងតំណាងក្រសួងពាក់ព័ន្ធមានដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រសួងធនធានទឹក និងឧតុនិយមជាដើម ដើម្បីធ្វើការពិភាក្សាផ្លាស់ប្ដូរយោបល់ ចែករំលែកបទពិសោធន៍ នៅក្នុងការពង្រឹងការយល់ដឹង



វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច:sg@na.gov.kh គេហទំព័រ: www.na.gov.kh

របស់សភា និងកិច្ចសហប្រតិបត្តិការពហុភាគីទៅលើទំនាក់ទំនងប្រទាក់ក្រឡារវាងសន្តិសុខស្បៀង ភាពធន់នឹងអាកាសធាតុ និងការវិនិយោគ ប្រកបដោយការទទួលខុសត្រូវក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ ស្របតាមគោលការណ៍ណែនាំអាស៊ាន ស្តីពីការលើកកម្ពស់ការវិនិយោគ ប្រកបដោយការទទួលខុសត្រូវ ក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ ព្រមទាំងក្របខ័ណ្ឌអនុវត្តរបស់សភាអាស៊ាន ស្តីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវក្នុងវិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើ ឆ្នាំ២០២៤-២០៣០ ( ASEAN RAI 2024-2030 )។

នៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នេះ មានកិច្ចប្រជុំសំខាន់ៗចំនួន៤ រួមមាន៖

**១- កិច្ចសន្ទនាគោលនយោបាយទី១៖** ប្រព័ន្ធស្បៀងអាហារដែលធន់នឹងអាកាសធាតុ និងការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវ៖ ជំរុញរបៀបវារៈ ASEAN RAI។

**២- កិច្ចសន្ទនាគោលនយោបាយទី២៖** ការជំរុញរបៀបវារៈ ASEAN RAI សម្រាប់សន្តិសុខស្បៀង៖ ការស្វែងយល់លើវិមាត្រសេដ្ឋកិច្ចនៃការវិនិយោគប្រកបដោយការទទួលខុសត្រូវ។

**៣- កិច្ចសន្ទនាគោលនយោបាយទី៣៖** ការពង្រឹងសកម្មភាពសភា និងភាពជាដៃគូពហុភាគី ដើម្បីសន្តិសុខស្បៀង និងអាកាសធាតុ៖ ការជំរុញរបៀបវារៈ ASEAN RAI។

**៤- កិច្ចសន្ទនាគោលនយោបាយទី៤៖** ពីកិច្ចសន្ទនាទៅជាសកម្មភាពជាក់ស្តែង៖ តួនាទីរបស់សមាជិកសភាក្នុងសន្តិសុខស្បៀង ភាពធន់នឹងការប្រែប្រួលអាកាសធាតុ និងការវិនិយោគប្រកបដោយការទទួលខុសត្រូវ។

កិច្ចប្រជុំស្តីពី "កិច្ចសន្ទនាជាមួយពហុភាគីពាក់ព័ន្ធរបស់សភាស្តីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវសម្រាប់សន្តិសុខស្បៀង និងអាកាសធាតុ៖ ជំរុញរបៀបវារៈអាស៊ានស្តីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវលើវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ" នឹងប្រារព្ធពិធីបិទ ក្រោមអធិបតីភាព ឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភា នៅព្រឹកថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៦។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦

**អគ្គលេខាធិការ**

**ឡេង ប៉េងឡុង**